## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ.១៤៣.០..សរាំង

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ករណីសំណើសុំការអនុញ្ញាតចាប់ដៃ គូសហការ វិនិ យោគ និងកែសម្រួលលក្ខន្តិកៈក្រុមហ៊ុន។

**យោង** ៖ -លិខិតលេខ៨៣៨៧ កសក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ចំពោះករណីសំណើរបស់ក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថីវ សុំការអនុញ្ញាតចាប់ដៃគូសហការវិនិយោគ លើដីសម្បទានសេដ្ឋកិច្ចដាំដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ ស្ថិតនៅស្រុកសំបូរ ខេត្តក្រចេះ និងកែសម្រួលលក្ខន្តិកៈក្រុមហ៊ុននោះ រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដូចខាងក្រោម ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថីវ សហការជាដៃគូវិនិយោគជាមួយក្រុមហ៊ុន GUANGDONG GUANGKEN RUBBER GROUP CO.,LTD ។

២-អនុញ្ញាតឲ្យក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថីវ ធ្វើការកែសម្រួលរចនាសម្ព័ន្ធដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន ដែលចេញដោយក្រសួងពាណិជ្ជកម្មគឺ៖ ក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថីវ មានម្ចាស់ភាគហ៊ុន ១.ក្រុមហ៊ុន GUANGDONG GUANGKEN RUBBER GROP CO.,LTD តំណាងដោយ លោក Zhong ,Weikun លោក Deng, Hanhua និងលោក Lu Jian ២. ក្រុមហ៊ុន ញូ វេនឈើរ រ៉ាប់ប៊ើរ ផ្លេនថេសិន តំណាងដោយលោក Yap Chin Seng និងលោក Yap Hai Ter ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងបាត់ចែងអនុវត្តតាមការគួរ ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុន អ៊ុយ

ចម្លងជូន:
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន
-សាលាខេត្តក្រចេះ
-ក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថីវ
-ក្រុមហ៊ុន ញូ វេនឈើរ រ៉ាប់ប៊ើរ ផ្លេនថេសិន
-ក្រុមហ៊ុនGUANGDONG GUANGKEN RUBBER GROP CO.,LTD
-ឯកសារ-កាលប្បវត្តិ